# សក្ខីកម្មក្នុងករណី00២ បន្តពីថ្ងៃម្សិលមិញ

*“បើទាំងអស់គ្នាជាខ្មាំងដូច្នេះ តើមាននរណាបម្រើបដិវត្តន៍ទៅ?”-- នួន ជា*

***ថ្ងៃទី១១ ខែមករា ឆ្នាំ២០១២***

***ដោយ រ៉េនឌល ឌីហ្វាលកូ***

*ប្រែសម្រួលដោយ ជា ផល្លា*

នៅថ្ងៃពុធ ទី១១ ខែមករា ឆ្នាំ២០១២នេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់ផ្តើមដំណើរការសវនាការបន្តពីម្សិលមិញ ។ នៅថ្ងៃនេះ អ្នកចូលរួមមកពីស្រុកពួក ខេត្តសៀមរាបបាន ធ្វើដំណើរតាំងពីយប់ជ្រៅដើម្បីមកឲ្យទាន់សវនាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលនឹងចាប់ផ្តើមនៅម៉ោង៩ៈ០០ព្រឹក ។ បន្ទាប់ពីចូលរួមសវនាការនៅពេលព្រឹករួចមក នៅពេលរសៀល មន្ត្រីកិច្ចការសារធារណរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បាននាំប្រជាជនទាំងនោះ ទៅទស្សនាគុកទួលស្លែង និងវាលពិឃាតជើងឯក ហើយត្រលប់ទៅលំនៅដ្ឋានវិញនៅថ្ងៃដដែល ។

## អង្គជំនុំជម្រះណែនាំមេធាវីការពារក្តីថា មិនត្រូវរំខានដំណើរការសវនាការ

អង្គជំនុំជម្រះចាប់ផ្តើមថ្ងៃនេះបានណែនាំទៅមេធាវីការពារក្តីថា មិនត្រូវរំខានដល់ដំណើរការសវនាការទេ ទោះបីជាជនជាប់ចោទចង់ស្នើចេញពីបន្ទប់សវនាការក៏ដោយ ។ មេធាវីការពារក្តីត្រូវរង់ចាំរហូតដល់ពេលសម្រាក លើកលែងក្នុងករណីបន្ទាន់ណាមួយ ។ ចៅក្រមនៃអង្គជំនុំជម្រះបាននិយាយថា អង្គជំនុំជម្រះនឹងមិន «យោគយល់» ដល់សំណើដែលបានបង្អាក់ដល់ដំណើរសវនាការដែលកំពុងតែដំណើរការទេ ។

## ការពិភាក្សាបន្តទាក់ទងនឹងភ័ស្តុតាងឯកសារ

ក្រោយពីសេចក្តីថ្លែងការណ៍បឋមរបស់ប្រធាន និល ណុន រួចមក ព្រះរាជអាជ្ញាត្រូវបានផ្តល់សិទ្ធិឲ្យសួរសំណួរបន្តទៅជនជាប់ចោទ នួន ជា ។ ព្រះរាជអាជ្ញាចាប់ផ្តើមសួរអំពីសេចក្តីថ្លែងការណ៍មួយចំនួនដែលបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តីទង់ក្រហមរបស់ខ្មែរក្រហម ដែលសំណួរមួយចំនួនព្រះរាជអាជ្ញាបានសួរខ្លះៗហើយកាលពីម្សិលមិញ ហើយ នួន ជា ផ្ទាល់ក៏បានជំទាស់ទៅនឹងឯកសារថតចម្លងរួចមកហើយដែរ ។ ព្រះរាជអាជ្ញាបានបង្ហាញថា សៀវភៅទង់ក្រហមលេខពិសេសដែលក្នុងនោះមានការបោះពុម្ពផ្សាយពីសុន្ទរកថារបស់ ប៉ុល ពត អាចយកមកប្រើការបានព្រោះសុន្ទរកថានោះក៏ត្រូវបានផ្សព្វផ្សាយតាមវិទ្យុនិងតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតដែរ ។ អង្គជំនុំជម្រះបានអនុញ្ញាត

ឲ្យព្រះរាជអាជ្ញាបន្តសួរសំណួរទៀត ព្រមទាំងបានរំឭកទៅភាគីផ្សេងទៀតឲ្យនៅស្ងៀមដោយមិនត្រូវនិយាយបន្ថែមអ្វីឡើយ ។

គ្រាន់តែចៅក្រមនិយាយចប់ភ្លាម មេធាវីការពារក្តីរបស់ អៀង សារី បានជំទាស់ដោយអះអាងថា កាលពីដំបូងអង្គជំនុំជម្រះបានអនុញ្ញាតថា ការប្រើប្រាស់ឯកសារដែលកំពុងតែមានបញ្ហាចម្រូងចម្រាសអាចប្រើបាន ដើម្បីជាឯកសារជំនួយនៅពេលសួរសំណួរប៉ុណ្ណោះ ហើយមិនត្រូវអានអ្វីដែលបានរៀបរាប់នៅក្នុងឯកសារនោះទេ ។ មេធាវីការពារក្តីរបស់ អៀង សារី បានបន្តទៀតថា កាលនោះចៅក្រមនិយាយថា «សម្តី...ដែលមានលក្ខណៈមិនសមរម្យនិងមិនមានការវិនិច្ឆ័យច្បាស់លាស់» ។

អង្គជំនុំជម្រះបានឆ្លើយតបថា សេចក្តីថ្លែងការណ៍របស់មេធាវីការពារក្តី គឺជាការជំទាស់ តែមេធាវីរូបនេះបែរជាយកលេសថាជា«ការយល់ឃើញ» ទៅវិញ ។ អង្គជំនុំជម្រះបានរំឭកទៅគ្រប់ភាគីទាំងអស់ថា ការពិភាក្សារឿងឯកសារនឹងយកមកនិយាយពេញមួយសប្តាហ៍ចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៩ ខែមករា នេះ ។ ជាមួយគ្នានោះ មេធាវីការពារក្តីរបស់ នួន ជា បានក្រោកឡើង ហើយបញ្ជាក់ទៅគ្រប់ភាគីទាំងអស់ថា កូនក្តីរបស់គាត់នៅតែទាមទាររកឯកសារដើមទាំងអស់របស់ទស្សនាវដ្តីទង់បដិវត្តន៍ និងសៀវភៅទង់ក្រហម ព្រមទាំងបានស្នើទៅព្រះរាជអាជ្ញាឲ្យបង្ហាញឯកសារដើមឲ្យបានឆាប់ ។

ចៅក្រម និល ណុន ហាក់បីដូចជាមួម៉ៅពេលដែលមេធាវីការពារក្តីរបស់ នួន ជា និយាយបែបនេះ និងបានរំឭកទៅមេធាវីការពារក្តីនោះថាបានលើកយកបញ្ហាច្រំដែលមកនិយាយ ។ ចៅក្រម និល ណុន បាននិយាយទៅកាន់មេធាវីជាតិរបស់ នួន ជា ថាកំពុងតែព្យាយាម«បកស្រាយខុស» ទៅនឹងអ្វីដែលអង្គជំនុំជម្រះបានបញ្ជាក់កាលពីលើកមុនទាក់ ទងទៅនឹងការដាក់បញ្ចូលឯកសារនៅចំពោះមុខតុលាការ និងបានណែនាំមេធាវីជាតិរូបនោះឲ្យទៅមើល«សេចក្តីសម្រេចរបស់អង្គសវនាការ» ឡើងវិញ ព្រោះអង្គជំនុំជម្រះមិនចង់យកបញ្ហានេះមកនិយាយម្តងទៀតទេ ។ នៅពេលដែលចៅក្រម និល ណុន ស្តីបន្ទោសមេធាវីជាតិរបស់ នួន ជា ដូច្នេះសាធារណជនដែលកំពុងតែអង្គុយមើលដំណើរការនេះសើចព្រោះពេញចិត្តទៅនឹងអ្វីដែលលោកចៅក្រមបន្ទោសមេធាវីរបស់នួន ជា ។ ក្រោយមក អង្គជំនុំជម្រះអនុញ្ញាតឲ្យព្រះរាជអាជ្ញាសួរសំនួរទៅ នួន ជា បន្តទៀត ។

## ព្រះរាជអាជ្ញាសួរសំណួរបន្ត

ព្រះរាជអាជ្ញាបានបន្តនូវសំនួរដោយសួរ នួន ជា អំពីសមាជបក្សឆ្នាំ១៩៦០ ពេលដែលបក្សកុម្មុយនីស្តកម្ពុជាត្រូវបានបង្កើតឡើង ។ ព្រះរាជអាជ្ញាបានសួរទៅ នួន ជា ថាតើមានអ្នកតំណាង

ភូមិភាគពាយ័ព្យ និងភូមិភាគឥសាន្តចូលរួមក្នុងសមាជនោះដែរឬទេ? នួន ជា បានឆ្លើយថា ជាការពិត អ្នកតំណាងមកពីភូមិភាគត្រូវតែចូលរួមក្នុងសមាជនោះ។ ព្រះរាជអាជ្ញាសួរបន្តទៀត នួន ជា មិនចាំទេថា តើនៅពេលណាទើបមានការបែងចែកជាភូមិភាគ និងពេលណាមានការតែងតាំងថ្នាក់ដឹកនាំតាមភូមិភាគនោះ?

នៅពេលសួរអំពីតួនាទីរបស់ ខៀវ សំផន ក្នុងបក្សកុម្មុយនីស្តកម្ពុជាក្នុងឆ្នាំ១៩៦០ នួន ជា បានឆ្លើយថា គាត់មិនដឹងពីសកម្មភាពរបស់ ខៀវ សំផន នៅពេលនោះទេព្រោះ ខៀវ សំផន ទាក់ទងជាមួយ“បញ្ញវន្ត” ។ នួន ជា ក៏បានបន្ទោសទៅព្រះរាជអាជ្ញាដោយសារតែមិនចាំនូវអ្វីដែលគាត់ប្រាប់កាលពីមុនរួចហើយថា ប៉ុល ពត បានប្រាប់គាត់ថា គាត់មិនត្រូវខ្វល់ខ្វាយជាមួយ“បញ្ញវន្ត” ទេ ។

នួន ជា នៅតែអះអាងថា គាត់មិនដឹងទេថា ខៀវ សំផន ចូលបក្សកុម្មុយនីស្តកម្ពុជា នៅពេលណានោះ។ ព្រះរាជអាជ្ញាបានសួរទៅ នួន ជា ថាតើគាត់សំដៅទៅលើនរណានៅពេលដែលគាត់និយាយពីអ្នកដែលប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជាថា “អ្នកឈ្លានពានបរទេស និងបរិវាររបស់វា” ពេលដែលគាត់និយាយនៅក្នុងសេចក្តីថ្លែងការណ៍បើកកាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០១១នោះ។ នួន ជា ហាក់បីដូចជានៅតែចចេសមិនឆ្លើយ និងបានបញ្ជាក់ថា សំនួរនេះគឺយកចេញពីសុន្ទរកថា ដែលគាត់ទាមទារឲ្យយកឯកសារដើមមកបង្ហាញ ។ ក្រោយមកព្រះរាជអាជ្ញាបានអះអាងឡើងវិញថា ពាក្យពេចន៍ទាំងនោះគឺ ជាពាក្យដែល នួន ជា និយាយកាលពីខែវិច្ឆិកាកន្លងទៅ ពេលដែលគាត់ថ្លែងទៅកាន់តុលាការ មិនមែនជាពាក្យពេចន៍ដែលដកស្រង់ចេញពីទស្សនាវដ្តីទេ ។ នួន ជា បានឆ្លើយតបវិញថា គាត់មិនចាំទេថា គាត់បានប្រើប្រាស់ពាក្យ “បរិវារ”ដែរឬអត់នោះនៅក្នុងសេចក្តីថ្លែងការណ៍បើកកាលពីខែវិច្ឆិកា ហើយបន្តទៀតថា គាត់“កម្រ” ប្រើពាក្យនោះណាស់ ។

បន្ទាប់មក ព្រះរាជអាជ្ញាបានណែនាំឲ្យក្រឡាបញ្ជីរបស់អង្គជំនុំជម្រះអានផ្នែកខ្លះរបស់ទស្សនាវដ្តីទង់បដិវត្តន៍ឲ្យឮៗដែលសរសេរអំពីក្រុមដែលបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថាជា“សត្រូវ”កាលពីសមាជបក្សឆ្នាំ១៩៦០ ។ នៅពេលព្រះរាជអាជ្ញាស្នើ នួន ជា ឲ្យបកស្រាយពីអ្វីដែលក្រឡាបញ្ជីទើបតែអានចប់នោះ នួន ជា បាននិយាយថា ពាក្យនោះមិនត្រឹមត្រូវទេ ហើយអ្នកនិយាយយកមកនិយាយនោះខុសពីអ្វីដែលបក្សកុម្មុយនីស្តកម្ពុជាបានបញ្ជាក់ ។ នួន ជា បានបញ្ជាក់ថា កាលនោះ មានសត្រូវតែពីរទេគឺ “ពួកចក្រពត្តិនិងដៃជើងរបស់វា” ហើយ នួន ជា បានបកបន្ថែមទៀតថា ពាក្យ “ដៃជើង” គឺសំដៅលើបុគ្គលណាដែល“លក់ខ្លួន”ឲ្យពួកចក្រពត្តិដែលជាម្ចាស់ដី ។ នួន ជា បានបញ្ជាក់ថា ពាក្យ“ប្រតិ

កិរិយា» គឺសំដៅទៅលើបុគ្គលទូទៅ«ដែលជិះទាស់» តែមានក្រុមប្រតិកិរិយាជាច្រើនប្រភេទដែលបានតវ៉ាប្រឆាំងដោយសារហេតុផលផ្សេងៗ ។

នៅពេលសួរសំនួរបន្តទៀត នួន ជា បានបញ្ជាក់ថា «ពាក្យនោះមិនត្រឹមត្រូវទាស់តែសោះ» នូវអ្វីដែលព្រះរាជអាជ្ញាអះអាងថា មន្ត្រីរបស់រដ្ឋាភិបាលមុនៗត្រូវបានចាត់ទុកថាជា «សត្រូវសក្តិភូមិ» ដោយបក្សកុម្មុយនីស្តកម្ពុជានោះ ។ នួន ជា បានបញ្ជាក់ថា អ្នកទាំងនោះមិនត្រូវបានចាត់ទុកថាជាសត្រូវដោយស្វ័យប្រវត្តិនោះទេ ហើយប្រភេទ «អភិជន» រួមមានមនុស្សល្អផង និងមនុស្សអាក្រក់ផង សូម្បីតែពួកសក្តិភូមិក៏ «មិនមែនអាក្រក់»ទាំងអស់នោះទេ ព្រោះអ្នកទាំងនោះក៏ជាអ្នកស្នេហាជាតិដែរ ។ នួន ជា បាននិយាយទៅកាន់ព្រះរាជអាជ្ញាថា មានមនុស្សល្អផង និងមិនល្អផងនៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា និងបញ្ជាក់បន្ថែមថា «លោកមិនត្រូវចាត់ទុកមនុស្សគ្រប់គ្នាជាសត្រូវទាំងអស់នោះទេ» ពីព្រោះការដែលនិយាយបែបនេះអាចបង្កឲ្យមានការ«បែកបាក់គ្នា» នៅក្នុងប្រទេស ។

ក្រោយមកព្រះរាជអាជ្ញាបានសួរទៅ នួន ជា ថាតើបក្សកុម្មុយនីស្តកម្ពុជាបានបែងចែកបុគ្គល «ល្អ» និង«អាក្រក់»ដោយរបៀបណា ។ នួន ជា បានឆ្លើយដោយរៀបរាប់ពីការស្នេហាជាតិនៅក្នុងមនោគមន៍បក្សកុម្មុយនីស្តកម្ពុជា ហើយបញ្ជាក់ទៀតថា សូម្បីតែបុគ្គលមកពីគ្រួសារអភិជនដែលជា «អ្នកជាតិនិយម» ត្រូវបានមើលឃើញថា ជាមនុស្សល្អនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាដែរ ។

នៅពេលសួរថា អំពីមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាដែលដកស្រង់ចេញពីទស្សនាវដ្តីយុវជនបដិវត្តន៍ នួន ជា បាននិយាយថា ឯកសារនោះពិបាកមើលណាស់ ដូច្នេះគាត់ចង់សុំ«ប៉ះ» ឯកសារនោះដើម្បីដឹងថាឯកសារនោះពិតឬមិនពិត ។ នៅពេលដែល នួន ជា ទទួលបានឯកសារនោះ គាត់បាននិយាយថា គាត់មិនដែលឃើញអក្សរបែបនេះពីមុនមកទេ ហើយគាត់បានអះអាងថា យុវជនមិនអាចរៀនអំពីអ្វីដែលបានរៀបរាប់នៅក្នុងឯកសារនេះទេ ដូច្នេះឯកសារនេះគឺជាឯកសារក្លែងក្លាយ ។ ព្រះរាជអាជ្ញាបានរំឭកទៅ នួន ជា ថា គាត់គ្រាន់តែចង់ឲ្យ នួន ជា រៀបរាប់ពីមាគ៌ាបក្ស ដែលបានរៀបរាប់នៅក្នុងឯកសារនេះប៉ុណ្ណោះ ។ ពេលនោះ នួន ជា បានឆ្លើយថា ឯកសារនោះ«មិនត្រឹមត្រូវទេ» ។ គាត់បាននិយាយថាបក្សកុម្មុយនីស្តកម្ពុជាបានកំណត់និយមន័យនៃពាក្យ«សក្តិភូមិ» ដោយបែងចែកជាច្រើនប្រភេទដូចជា «ពួកសក្តិភូមិម្ចាស់ដីនិងពួកប្រតិកិរិយាដែលឃោរឃៅបំផុត» តែ នួន ជា បានបញ្ជាក់ថា «មិនមែនម្ចាស់ដីទាំងអស់សុទ្ធតែសក្តិភូមិទេ ហើយពាក្យនេះកំណត់មិនត្រឹមត្រូវទេ» ព្រោះការហៅបែបនេះអាចធ្វើឲ្យប្រទេសជាតិ«បែកបាក់គ្នា» ។ នួន ជា បានអះអាងទៀតថា បក្សកុម្មុយនីស្តកម្ពុជាចង់«បង្កើតមិត្ត»ជាមួយមនុស្សជាច្រើនក្រុមតាមតែអាចធ្វើទៅបានដើម្បីកសាងកម្លាំងនៅក្នុងប្រទេស និងដើម្បីបន្ថយចំនួនសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា ។

នួន ជា ហាក់បីដូចជាធុញថប់សារជាថ្មីទៀត នៅពេលដែលព្រះរាជអាជ្ញាស្នើឲ្យគាត់រៀបរាប់ពីឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជាដែលបញ្ជាក់ថា សមាជិករបស់រាជរដ្ឋាភិបាលមុន ចាប់តាំងពីថ្នាក់លើដល់ថ្នាក់ក្រោម រហូតដល់ស្មៀនតាមភូមិឃុំត្រូវបានចាត់ទុកថា ជាសត្រូវ«ស្លាប់រស់»របស់បក្សកុម្មុយនីស្តកម្ពុជា ។ ត្រង់ចំណុចនេះ នួន ជា បានបញ្ជាក់ទៀតថា នេះមិនត្រឹមត្រូវទេព្រោះ«គ្មានក្រុមណាមួយត្រូវបានចាត់ទុកថាជាសត្រូវរបស់បក្សទេ» មានតែ«បុគ្គលមួយចំនួនប៉ុណ្ណោះ ដូចជាគិញជាដើម ដែលធ្វើឲ្យលេចព័ត៌មានលឺដល់ខ្មាំងធ្វើឲ្យខ្មាំងអាចវាយប្រហារមកលើបក្សបាន» នួន ជា បានបន្ទោស ព្រះរាជអាជ្ញាថា មិនត្រូវនិយាយ«ទូទៅ»អំពីមនុស្សទាំងឡាយទេ ព្រមទាំងបានសួរទៅព្រះរាជអាជ្ញាថា «បើទាំងអស់គ្នាជាខ្មាំងដូច្នេះ តើមាននរណាបម្រើបបដិវត្តន៍ទៅ? នួន ជា បានបន្តទៀតថា «យើងព្យាយាមបន្ថយចំនួនសត្រូវ និងបង្កើតមិត្តឲ្យបានច្រើនតាមតែអាចធ្វើទៅបាន នេះគឺជាពាក្យស្លោករបស់យើង» ។ នួន ជា បន្តទៀតថា ទោះបីជា គាត់ខឹងនិងធុញថប់ចំពោះបញ្ហានេះក៏ដោយ ក៏គាត់«មិនមើលងាយ» ឬ«មើលថោក» លោក ជា លីសាក់ ដែលជាសហព្រះរាជអាជ្ញារងអន្តរជាតិដែរ ព្រោះលោក ជា លីសាក់ មិនមានបទពិសោធន៍ជាមួយ«កសិករក្រីក្រ»នៅក្នុងប្រទេសកម្ពុជា ដូច្នេះគាត់មិនយល់ពីស្ថានភាពនោះទេ ។

ពេលដែល នួន ជា និយាយបែបនេះលោកចៅក្រម និល ណុន បានរំឭកទៅ នួន ជា ថាត្រូវតែឆ្លើយសំណួរដោយសាមញ្ញ និងមិនត្រូវងាកមកនិយាយពីប្រធានបទផ្សេងទេ ។ ទោះបីជាមានការរំឭកពីសំណាក់លោកចៅក្រមជាច្រើនសារក៏ដោយ ក៏មេធាវីរបស់ នួន ជា នៅតែក្រោកឈរ និងថ្លែងនៅកាន់សវនាការថា មុនបដិវត្តន៍ខ្មែរក្រហម ប្រជាជនកម្ពុជាដែលរស់នៅទីក្រុង មិនទាំងស្គាល់ដើមស្រូវផង ពេលដែលអ្នកទាំងនោះទៅដល់ជនបទ ឃើញដើមស្រូវប្រឡំថាជាដើមស្មៅទៅវិញ ។ នួន ជា បានបន្ថែមថា «ទស្សនៈ»របស់កសិករក្រីក្រនៅសម័យនោះមាន «ភាពខុសគ្នាខ្លាំងណាស់»ទៅនឹងប្រជាជននៅទីក្រុងដែលរីករាយជាមួយនិង «ស្រី ស្រា ល្បែង» ។

ជាថ្មីម្តងទៀតលោចៅក្រម និល ណុន មានអារម្មណ៍មួរម៉ៅ និងបានប្រាប់ទៅ នួន ជា យ៉ាងម៉ឺងម៉ាត់ម្តងទៀតឲ្យឆ្លើយទៅនឹងសំណួរដែលបានសួរទៅបានហើយ ។

ព្រះរាជអាជ្ញាបានបន្តនូវសំណួរទៅ នួន ជា ថាតើមានគោលបំណងអ្វីសំខាន់ទេដែលបក្សកុម្មុយនីស្តកម្ពុជា ប្តូរពីបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យទៅជាបដិវត្តន៍សង្គមនិយមប្រជាជាតិវិញនោះ? មុននឹងឆ្លើយ នួន ជា បានទាមទារឲ្យព្រះរាជអាជ្ញាបង្ហាញភ័ស្តុតាងទាក់ទងទៅនឹងឯកសារនោះសិន ។ ព្រះរាជអាជ្ញាបានបញ្ជាក់ម្តងទៀតថា គាត់គ្រាន់តែចង់សួរសំណួរទូទៅប៉ុណ្ណោះ មិនមែនដកស្រង់ចេញពីឯកសារជាក់លាក់ណាមួយនោះទេ តែគាត់បានដកស្រង់ចេញពីអ្វីដែល នួន ជា បាននិយាយរួចហើយ

កាលពីការសេចក្តីថ្លែងការណ៍លើកមុនៗ ។ ទោះបីជាព្រះរាជអាជ្ញានិយាយបែបនេះក៏ដោយ នួន ជា នៅតែប្រកែកមិនឆ្លើយតបអ្វីទាំងអស់ ។

បន្ទាប់ពី នួន ជា ធ្វើការបដិសេធមិនឆ្លើយ ព្រះរាជអាជ្ញាបានប្តូរសំណួរដោយសួរថា តើបក្សកុម្មុយនីស្តកម្ពុជាមានដែលដាក់ឈ្មោះអ្នកមូលធនថា ជាខ្មាំងដែរឬទេ? ពេលនោះ នួន ជា បានប្រកែកថា ខ្មែរក្រហមមិនដែលចាត់ទុកអ្នកមូលធនទាំងអស់ថា ជាខ្មាំងទេ ។ ស្របពេលនោះដែរ នួន ជា ហាក់បីដូចជាបង្ហាញនូវការធុញទ្រាន់ទៅនឹងសំនួររបស់ព្រះរាជអាជ្ញា ដែលបានចោទសួរមកគាត់ព្រមទាំងបានណែនាំទៅព្រះរាជអាជ្ញាថា ពួកមូលធននិងមូលធននិយមមានភាពខុសគ្នា ហើយបញ្ជាក់ទៀតថា បក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងមូលធននិយម តែបក្សមិនបានចាត់ទុកពួកមូលធន ជាខ្មាំងដោយស្វ័យប្រវត្តិនោះទេ ។

ម្តងនេះ នួន ជា នៅតែប្រកែកមិនព្រមឆ្លើយពេលដែលព្រះរាជអាជ្ញាសួរមកកាន់គាត់ ។ នួន ជា បានបដិសេធជាថ្មីថា បក្សកុម្មុយនីស្តកម្ពុជាមិនបានអនុម័តឲ្យប្រើប្រាស់ពាក្យ “ហិង្សាបដិវត្តន៍” នៅក្នុងសមាជឆ្នាំ១៩៦០ទេ តែគាត់បានបញ្ជាក់ថា “ការតស៊ូនយោបាយ” នៅតែជាកិច្ចការដ៏សំខាន់របស់បក្សកុម្មុយនីស្តកម្ពុជាដដែល ហើយក្រោយពីសមាជនោះមក “ការតស៊ូដោយអាវុធ” ធ្វើឡើងគ្រាន់តែដើម្បី“ការពារកម្មាភិបាលប៉ុណ្ណោះ” ។

ក្រោយមក ព្រះរាជអាជ្ញាបានសួរទៅ នួន ជា អំពីសុន្ទរកថាដែលគាត់បានថ្លែងដើម្បីប្រារព្ធខួបកងទ័ពបដិវត្តន៍កម្ពុជា ។ នួន ជា បានឆ្លើយថា គាត់មិនមែនមានឋានៈជាយោធារបស់បក្សទេ គឺ ប៉ុល ពត ជាអ្នកថ្លែងសុន្ទរកថាអំពីបញ្ហានេះក្នុងនាមជាអគ្គបញ្ជាការយោធា ។ ព្រះរាជអាជ្ញាបានចង្អុលបង្ហាញថា មានឯកសារមួយដែលបោះពុម្ពផ្សាយអំពីសម្តីរបស់ នួន ជា ក្នុងនាមជា“នាយករដ្ឋមន្ត្រីស្តីទី”របស់កម្ពុជាប្រជាធិបតេយ្យ ។ ចំពោះបញ្ហានេះ នួន ជា បានឆ្លើយថា នៅពេលនោះគាត់ និង ប៉ុល ពត “មានវ័យចំណាស់” ហើយ សុន សេន ត្រូវមកចូលមកជំនួសគាត់ ។ សុន សេន ជាអ្នកស្នងពី ប៉ុល ពត បើសិនជាមានរឿងអ្វីមិនល្អណាមួយកើតឡើងចំពោះ ប៉ុល ពត ។ នួន ជា បានបដិសេធទៀតថា គាត់មិនដែលតំណាងជានាយករដ្ឋមន្ត្រីស្តីទីរបស់កម្ពុជាប្រជាធិបតេយ្យនោះទេមានតែ សុន សេន ប៉ុណ្ណោះជាអ្នកចូលមកជំនួសតំណែងរបស់ ប៉ុល ពត ប្រសិនបើគាត់ឈឺ និងចាស់ជរា ។ ដោយដឹងថា នួន ជា ចេះតែបដិសេធមិនឆ្លើយ ព្រះរាជអាជ្ញាបានបន្តដំណើរការទៅមុខទៀត ដោយប្រាប់ថា ខ្លួននឹងបន្តសួរទៅនៅថ្ងៃក្រោយទៀត ។ នៅពេលដែលព្រះរាជអាជ្ញាព្យាយាមសួរពីសុន្ទរកថាដែល នួន ជា បានថ្លែងនោះ នួន ជា នៅតែទាមទារចង់អានឯកសារដើមពីព្រះរាជអាជ្ញា ។ ព្រះរាជ

អាជ្ញាបានឆ្លើយតបថា គាត់មិនបន្តដំណើរការទៅមុខទេ ហើយនឹងទុកឯកសារឲ្យ នួន ជា អាននៅពេលយប់ ទើបចាប់ផ្តើមសួរនៅថ្ងៃក្រោយទៀតក្រោយពី នួន ជា បានពិនិត្យមើលឯកសាររួចហើយ ។

ប្រធានបទក្រោយមកទៀត គឺទាក់ទងទៅនឹងអត្ថបទមួយនៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍ដែលរៀបរាប់ថា បក្សកុម្មុយនីស្តកម្ពុជាបាននិយាយពីពាក្យ "ស្របច្បាប់" និង"មិនស្របច្បាប់"របស់បដិវត្តន៍ ។ នួន ជា នៅតែជំទាស់ដដែលទៅនឹងឯកសារថតចម្លងហើយទាមទាចង់បានឯកសារដើម ។ ពេលនោះ ចៅក្រម និល ណុន បានរំឭកទៅ នួន ជា ជាថ្មីម្តងទៀតថា អង្គជំនុំជម្រះបានបញ្ជាក់ ហើយថា ឯកសារថតចម្លងនេះត្រូវប្រើបណ្តោះអាសន្នសិន និងរង់ចាំដល់ពេលសវនាការលើភ័ស្តុតាងមកដល់ ។ លោកចៅក្រមបានបញ្ជាក់ថា បើ នួន ជា បដិសេធមិនឆ្លើយដោយសារតែឯកសារចម្លងនេះ អង្គសវនាការនិងសម្រេចថា ជនជាប់ចោទ នួន ជា សុំសិទ្ធមិននិយាយអ្វីទាំងអស់ ។ ទន្ទឹមនឹងនោះ នួន ជា បានបកស្រាយដោយបង្ហាញនូវការយល់ព្រមចំពោះចៅក្រម ។ ពេលនោះមេធាវី ការពារក្តីរបស់ នួន ជា បានក្រោកឡើងបញ្ជាក់ថា នួន ជា មិនសុំសិទ្ធនៅស្ងៀមទេ តែ នួន ជា តវ៉ាអំពីបញ្ហាភាពពិតរបស់ឯកសារ ហើយគាត់បាន"ណែនាំ"ទៅព្រះរាជអាជ្ញាថា មិនត្រូវយកឯកសារមិនច្បាស់លាស់មកប្រើប្រាស់នៅចំពោះមុខអង្គសវនាការនោះទេ ។

ចៅក្រម និល ណុន បានបញ្ជាក់ទៅមេធាវីរូបនោះថា នួន ជា ផ្ទាល់បាននិយាយហើយ គាត់សុំសិទ្ធិនៅស្ងៀមដោយមិនឆ្លើយតបចំពោះឯកសារថតចម្លង ។ តែព្រះរាជអាជ្ញានៅតែអាចមានសិទ្ធិបង្ហាញឯកសារនៅក្នុងតុលាការបាន ដោយយោងទៅតាមការណែនាំរបស់អង្គសវនាការ ប្រសិនបើឯកសារនោះមានការពាក់ព័ន្ធទៅនឹងប្រវត្តិចលនាខ្មែរក្រហម ។

ព្រះរាជអាជ្ញាបានបន្តសួរទៅ នួន ជា ថាតើពិតដែលឬទេដែលសមាជ កាលពីឆ្នាំ១៩៦០ បក្សកុម្មុយនីស្តកម្ពុជាបានប្រើប្រាស់ពាក្យ "ស្របច្បាប់ ឬមិនស្របច្បាប់" ជាវិធីក្នុងការសម្រេចគោលដៅរបស់បដិវត្តន៍នោះ ។ នួន ជា នៅតែរក្សាជំហរមិនឆ្លើយតបអ្វីនឹងសំនួរនោះទេ ។

នួន ជា ក៏បានជំទាស់មិនឆ្លើយទៅនឹងសំណួរដែលព្រះរាជអាជ្ញាសួរថា ក្រោយសមាជឆ្នាំ ១៩៦០ សមាជិកបក្សទាំងអស់តម្រូវឲ្យដាក់ពាក្យសុំជាសមាជិកឡើងវិញនោះទេ ។ ចំណុចនេះត្រូវបានរៀបរាប់នៅក្នុងសៀវភៅដែលសរសេរដោយ ខៀវ សំផន ។

នៅពេលសួរថា តើនរណាជាអ្នកប្តូរគោលនយោបាយបក្សដែលសម្រេចដោយសមាជបក្សនោះ នួន ជា បានបញ្ជាក់ថា "សមាជបក្សពេញអង្គ" គឺជាអង្គភាពតែមួយគត់ដែលអាចប្តូរមាគ៌ាបក្សកុម្មុយនីស្តកម្ពុជាបាន ចំណែកឯគណៈអចិន្ត្រៃយ៍និងគណៈមជ្ឈឹមបក្សមិនអាចសម្រេចបានទេ ។ មានតែសមាជបក្សពេញអង្គ ដែលចូលរួមដោយសមាជិកបក្សទាំងអស់ទូទាំងប្រទេសទើបអាចផ្លាស់ប្តូរគោល

នយោបាយផ្សេងៗរបស់បក្សបាន ។ នួន ជា បានបញ្ជាក់ទៀតថា គាត់មិនអាចនឹកឃើញមាគ៌ាបក្សមួយចំនួនដែលបានផ្លាស់ប្តូរមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ទេ ។

ក្រោយមក ព្រះរាជអាជ្ញាបានសួរទៅ នួន ជា ថាហេតុអ្វីបានជាកូនកសិករត្រូវបានជ្រើសរើសឲ្យចូលបម្រើ«អង្គភាពការពារសម្ងាត់»របស់បក្សកុម្មុយនីស្តកម្ពុជា ។ នួន ជា បានបញ្ជាក់ឲ្យដឹងថា អ្នកដែលនៅក្នុងអង្គភាពនេះ «មិនមែនជាយោធា»ទេ តែជា«អ្នកអមដំណើរ»កម្មាភិបាលក្មេងៗទាំងនោះមិនមានអាវុធអ្វីទេ មានតែកាន់ដំបង ញញួរ និងកាំបិតប៉ុណ្ណោះ ។ នួន ជា បានរំឭកថា «បើតាមខ្ញុំចាំ កូនរបស់កសិករទាំងនេះត្រូវប្រើឲ្យទៅឃ្វាលគោ និងនាំផ្លូវកម្មាភិបាល ពេលកម្មាភិបាលធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ ។ កម្មាភិបាលបាលនោះគឺជាសាច់ញាត្តិរបស់ក្មេងៗទាំងនោះ ។ ពេលដែលកម្មាភិបាលទៅកន្លែងណាមួយ គេប្រើកូនក្មួយរបស់គេដើម្បីនាំទៅដល់គោលដៅ» ។

នួន ជា បានបញ្ជាក់ទៀតថា ក្មេងអាយុពី១៤ទៅ១៥ឆ្នាំធ្វើការនៅក្នុងអង្គភាពការពារសម្ងាត់នេះ នៅក្នុងរវាងពីឆ្នាំ១៩៦១និង១៩៦៦ អង្គភាពនេះមិនមានមនុស្សទេ ។ តែអ្នកភូមិបានបង្កើតអង្គភាពនេះដើម្បី«ការពារខ្លួន និងសុវត្ថិភាពផ្ទាល់ខ្លួន» ។

ក្រោយមក ព្រះរាជអាជ្ញាបានស្នើទៅ នួន ជា ឲ្យបកស្រាយអំពីអត្ថបទមួយនៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍ដែលបញ្ជាក់ថា ក្នុងឆ្នាំ១៩៦៦ គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាសម្រេចថា នឹងបំពាក់អាវុធដល់អង្គភាពការពារសម្ងាត់ និងរៀបរាប់កម្លាំងនោះឡើងវិញជា«កងឈ្លប» ព្រោះ«ស្ថានភាពស្លាប់រស់»រវាងកម្លាំង «បដិវត្តន៍និងកងប្រឆាំងបដិវត្តន៍» បានរីកធំធាត់យ៉ាងខ្លាំង ។ ពេលនោះ នួន ជា មិនបានឆ្លើយឲ្យចំទៅនឹងសំនួរទេ ព្រោះគាត់ចង់មើលឯកសារដើមសិន តែគាត់បានបញ្ជាក់ថា អ្នកភូមិរួបរួមគ្នា ដើម្បីការពារខ្លួនដោយមិនបានពឹងអង្គការខ្មែរក្រហមឲ្យជួយទេ ។ នួន ជា បានបដិសេធមិនបកស្រាយទៅនឹងសេចក្តីសម្រេចរបស់គណៈមជ្ឈិមបក្ស ហើយគាត់បានបញ្ជាក់ថា នៅពេលនោះបក្សកុម្មុយនីស្តកម្ពុជាមិនអាចបំពាក់អាវុធដល់ប្រជាជនបានទេ ព្រោះបក្សមិនមានអាវុធគ្រប់គ្រាន់ ។ នួន ជា បានបញ្ជាក់ទៀតថា បក្សកុម្មុយនីស្តកម្ពុជាគ្រាន់តែជួយ«រួបរួមប្រជាជនប៉ុណ្ណោះ» ដោយជួយធ្វើកិច្ចការមួយចំនួនដូចជា «ជួយធ្វើស្រែចម្ការ»ជាដើម ។

### នួន ជា និង អៀង សារី សុំសិទ្ធិមិនមានវត្តមាននៅក្នុងសវនាការ

ក្រោយពី នួន ជា ឆ្លើយរួច អង្គសវនាការប្រកាសសម្រាកអាហារថ្ងៃត្រង់ ។ តែមុននឹងសម្រាក នួន ជា បានស្នើសុំទៅចៅក្រមចេញពីបន្ទប់សវនាការដោយសារបញ្ហាសុខភាព ។ អង្គជំនុំជម្រះសម្រេចយល់ព្រម តែមេធាវីរបស់ នួន ជា ត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរមួយមកកាន់អង្គជំនុំជម្រះ ។

ក្រោយពីចៅក្រមនិយាយចប់ មេធាវីរបស់ អៀង សារី បានក្រោកឈរហើយនិយាយថា អៀង សារី ក៏សុំសិទ្ធិចេញពីបន្ទប់សវនាការដែរនៅពេលរសៀលនេះ ហើយមេធាវីនឹងប្រគល់លិខិតជាលាយលក្ខណ៍អក្សរទៅឲ្យចៅក្រម ។

គួរបញ្ជាក់ផងដែរថា សម្រាប់ដំណើរការនៅពេលរសៀល អៀង សារី និង នួន ជា មិនមានវត្តមាននៅក្នុងបន្ទប់សវនាការទេ តែជនជាប់ចោទទាំងពីរនឹងតាមដានដំណើរការសវនាការ នៅក្នុងបន្ទប់រង់ចាំវិញ ។

## ដើមបណ្តឹងរដ្ឋប្បវេណី ក្លាន ហ៊ីត បន្តធ្វើសក្ខីកម្ម

នៅពេលរសៀល អង្គជំនុំជម្រះចាប់ផ្តើមសួរសំណួរបន្តទៅកាន់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្លាន ហ៊ីត ដែលបានធ្វើសក្ខីកម្មរួចហើយកាលពីម្សិលមិញ និងកាលពីខែមុនៗ នៅពេលនេះ ក្រុមការពារក្តីនីមួយៗមានឱកាសក្នុងការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។

មេធាវីរបស់ នួន ជា បានចោទជាសំណួរទាក់ទងទៅនឹងរយៈពេលដែល ក្លាន ហ៊ីត ចូលបដិវត្តន៍ខ្មែរក្រហម ។ ក្លាន ហ៊ីត បានឆ្លើយថា គាត់បានចូលបដិវត្តន៍ព្រោះគាត់ខ្លាច ហើយគាត់បានឮពីអង្គការ ។ ក្លាន ហ៊ីត បាននិយាយថា អង្គការចេញមកពីព្រៃ«ដើម្បីអប់រំយើង» គាត់ខ្លាចអង្គការនេះណាស់ ។

ក្រោយមក ក្លាន ហ៊ីត បានរំឭកថា ក្នុងឆ្នាំ១៩៧៥ អង្គការហៅគាត់ទៅចូលរួមមេទ្ញេញ ពេលនោះ គាត់បានឃើញ នួន ជា ដែលមានរាងទាប មាឌធំ និងមុខធំ។ ក្លាន ហ៊ីត បានឲ្យដឹងថា គាត់មិនដឹងថា នួន ជា ជានរណាទេ តែឈ្មោះរបស់ នួន ជា ត្រូវបានប្រកាសនៅក្នុងអង្គមេទ្ញេញនោះ ។ នៅពេលសួរបន្តទៅកាន់ ក្លាន ហ៊ីត អំពីអត្តសញ្ញាណរបស់ នួន ជា នោះ គាត់បានចង្អុលទៅ នួន ជា ហើយបញ្ជាក់ច្បាស់ៗថា “ខ្ញុំឃើញគាត់! ខ្ញុំឃើញគាត់ផ្ទាល់ភ្នែក” ។

ក្លាន ហ៊ីត បាននិយាយទៀតថា គាត់បានជួប ប៉ុល ពត, អៀង សារី និងអ្នកផ្សេងទៀតនៅខេត្តរតនគិរី មុនឆ្នាំ១៩៧៥ ។ ក្លាន ហ៊ីត បានបញ្ជាក់ថា ប៉ុល ពត មាន«ក្បាលពោះធំ តែក្បាលតូច» ។ នៅពេលនោះ នរណាក៏និយាយពីរឿងនេះដែរ ដោយនិយាយថា គេមិនដែលឃើញនរណាដែលមានក្បាលពោះធំនិងក្បាលតូចដូច្នេះទេ ។ ក្លាន ហ៊ីត បានបញ្ជាក់ថា មុនឆ្នាំ១៩៧៥ អៀង សារី បានប្រាប់គាត់ថា វៀតណាមគឺជាមិត្តរបស់បក្សកុម្មុយនីស្តកម្ពុជា តែក្រោយឆ្នាំ១៩៧៥ អៀង សារី បានប្រាប់គាត់វិញថា វៀតណាមគឺជាសត្រូវរបស់យើង ព្រមទាំងបានណែនាំគាត់ឲ្យហៅ វៀតណាមថា ជា “យួន” ។ នៅពេលសួរអំពីការជម្លៀសប្រជាជនចេញពីទីក្រុង ក្លាន ហ៊ីត បានបញ្ជាក់ថា ដោយសារតែតំបន់ដែលគាត់គ្រប់គ្រងជាតំបន់តូច ដូច្នេះមិនមានប្រជាជនជម្លៀសមកតំបន់គាត់ទេ

តែគាត់បានឃើញអ្នកទីក្រុងប្រមាណជា៨០០នាក់ ត្រូវបានបញ្ជូនទៅកន្លែងផ្សេងៗជិតតំបន់របស់គាត់ ។ ក្វាន ហ៊ីត បានបញ្ជាក់ថា «ប្រជាជនថ្មី» ដែលទើបតែជម្លៀស ត្រូវបានចាត់តាំងឲ្យធ្វើទំនប់ តែប្រជាជនថ្មី និង«អ្នកមូលដ្ឋាន» ធ្វើការជាមួយគ្នាអស់រយៈពេលប្រាំពីរថ្ងៃពេញពេលធ្វើទំនប់មួយ ។

ក្វាន ហ៊ីត បានបញ្ជាក់ទៀតថា គាត់មិនបានឃើញ«រឿងល្អឬអាក្រក់» ដូចជាការអត់ឃ្លាន «ដោយផ្ទាល់ភ្នែកទេ» តែគាត់ដឹងថា លក្ខខណ្ឌរស់នៅមានការលំបាកណាស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលដែលក្រុមការពារក្ដីរបស់ នួន ជា កំពុងសួរអំពីព្រឹត្តិការណ៍ក្នុងឆ្នាំ១៩៧៨ ព្រះរាជអាជ្ញា បានបដិសេធដោយណែនាំទៅអង្គជំនុំជម្រះឲ្យរំឭកទៅមេធាវីការពារក្ដីឲ្យកំណត់សំនួររបស់ខ្លួន ។

នៅពេលសួរអំពីហេតុការណ៍ទូទៅក្នុងទីក្រុងភ្នំពេញក្នុងខែមេសា ឆ្នាំ១៩៧៥ ក្វាន ហ៊ីត បានបញ្ជាក់ថា ទីក្រុងមានសភាព«ស្ងាត់ជ្រាប» ហើយថា គាត់ឃើញតែចុងភៅពីរបីនាក់ប៉ុណ្ណោះ ។

ក្រោយមក ក្វាន ហ៊ីត បានបញ្ជាក់ទៀតថា ក្នុងខែមករា ឆ្នាំ១៩៧៩ គាត់មកទីក្រុងភ្នំពេញម្ដងទៀតក្រោយពីគាត់ត្រូវបានចោទថា ជាគិញរបស់វៀតណាម ។ កាលនោះ គាត់និងអ្នកផ្សេងទៀតត្រូវបានកោះហៅឲ្យមកប្រជុំទៅភ្នំពេញ អំឡុងពេលនោះ មានកម្មាភិបាលជាន់ខ្ពស់មិនស្គាល់ឈ្មោះម្នាក់បានប្រាប់គាត់ថា បន្តិចទៀតវៀតណាមនឹងវាយយកទីក្រុងភ្នំពេញហើយ ។ មេដឹកនាំទាំងអស់នេះបានប្រាប់ទៅអ្នកចូលរួមក្នុងកិច្ចប្រជុំនោះថា នឹងចាកចេញរៀងៗខ្លួន ។ មួយថ្ងៃក្រោយមក ក្វាន ហ៊ីត បានឃើញឧត្ដម្ភាចក្រពីរគ្រឿងហោះចេញពីទីក្រុងភ្នំពេញ ។ ក្រោយមកគាត់បានឃើញកងការពាររបស់មេដឹកនាំទាំងនោះ«ដូនទឹកភ្នែក» ព្រោះមេរបស់ខ្លួនទៅចោល ។

បន្ទាប់មក ក្វាន ហ៊ីត បានបញ្ជាក់ថា គាត់មិនចង់«ប្ដឹង»នឹងមេដឹកនាំជាន់ខ្ពស់នោះទេ តែគាត់ចង់ដឹងការពិត ហើយគាត់បន្ថែមថា «យើងចាត់ទុកគ្នាដូចបងប្អូននៅពេលដែលយើងចូលបដិវត្តន៍ ...តែអង្គការប្រាប់យើងថា យើងត្រូវតែវាយវៀតណាម» ។

នៅពេលសួរថា តើគាត់ចង់បានអ្វីពីតុលាការនេះ ក្វាន ហ៊ីត បានឆ្លើយថា គាត់«ចង់បានមានជីវិតរស់» ដែលការនិយាយបែបនេះធ្វើឲ្យអ្នកចូលរួមសើចកក្អឹក ។ ក្វាន ហ៊ីត បានបកស្រាយនូវសម្ដីរបស់គាត់ថា គាត់ចង់និយាយថា អ្វីដែលគាត់បានធ្វើក្នុងរបបខ្មែរក្រហម គឺគាត់ធ្វើតាមតែបញ្ជារបស់ថ្នាក់ដឹកនាំប៉ុណ្ណោះ មិនមែនធ្វើដោយចិត្តរបស់គាត់ទេ ។ បន្ទាប់មកមេធាវីរបស់ នួន ជា និង អៀង សារី បានបញ្ចប់ការសួរនាំ ។

នៅពេលសួរអំពីការដាក់ពាក្យសុំធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណី ក្វាន ហ៊ីត បានសួរទៅវិញថាតើ «រដ្ឋប្បវេណី» មានន័យថាម៉េច? ។ ពេលនោះគាត់បានបដិសេធថា គាត់មិនបាន «ដាក់ពាក្យបណ្ដឹង» ទេ តែ«អង្គការស្នើឲ្យគាត់» ឆ្លើយសំនួរខ្លះ ។ ក្វាន ហ៊ីត ចង់បញ្ជាក់ថា អង្គជំនុំជម្រះវិសាមញ្ញក្នុង

តុលាការកម្ពុជាតឹងរ៉ឹងដូចមេរបស់ខ្លួនកាលពីជំនាន់ខ្មែរក្រហមដែរ ។ ក្វាន ហ៊ីត បានបន្តទៀតថា គាត់មិនអាចមើលឯកសារអ្វីបានទេ ព្រោះគាត់ល្ងិតល្ងង់ តែគាត់បានបញ្ជាក់ថា គាត់បាននិយាយការពិតរហូតពេលដែលគាត់និយាយប្រាប់តុលាការ ។

ក្រោយមក ក្វាន ហ៊ីត បានបញ្ជាក់ទៀតថា គាត់ស្គាល់អ្នកដាក់ពាក្យបណ្តឹងម្នាក់ទៀត ឈ្មោះ រម៉ម យុន ដែលបានធ្វើសក្ខីកម្មកាលពីថ្ងៃម្សិលមិញព្រោះអ្នកទាំងពីរនេះគឺជាអ្នកជិតខាងគ្នានៅក្នុងភូមិតែមួយ ។ ក្វាន ហ៊ីត បានបញ្ជាក់ទៀតថា អ្នកស៊ើបអង្កេតមកពីសាលាក្តីខ្មែរក្រហមសួរនាំគាត់ខុសទីតាំងគ្នា និងពេលខុសគ្នា ។ ក្រោយមក មេធាវីរបស់ អៀង សារី បានអានផ្នែកខ្លះក្នុងអត្ថបទសម្ភាសរបស់ ក្វាន ហ៊ីត ដែលកាលនោះគាត់បាននិយាយថា គាត់ចូលបដិវត្តន៍ដោយគ្មានការ បង្ខិតបង្ខំទេ ។ ក្វាន ហ៊ីត បាននិយាយថា គាត់ប្រើពាក្យ "បង្ខំ" ព្រោះកាលនោះកម្មាភិបាលខ្មែរក្រហម "បានបញ្ចុះបញ្ចូលគាត់និងអប់រំគាត់" ហើយគាត់ត្រូវបានអន្ទងឲ្យចូលបដិវត្តន៍ ព្រោះគាត់មិនចេះអក្សរ និងងាយស្រួលបញ្ចូលមនោគមន៍វិជ្ជា ។ គាត់បានបកស្រាយទៀតថា គាត់ចូលបដិវត្តន៍ព្រោះគាត់"ខ្លាច" ហើយ"ជារឿងគ្មានប្រយោជន៍ដែលប្រឆាំង"នឹងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ។ ក្វាន ហ៊ីត បានបញ្ជាក់ថា "អ៊ឹ យ៉ា" ដែលបានចូលបដិវត្តន៍ដោយស្ម័គ្រចិត្តក៏ត្រូវខ្មែរក្រហមយកទៅសម្លាប់ដែរ ។ ក្រោយពីសួរសំណួរបន្តទៀត ក្វាន ហ៊ីត បានសារភាពដោយចំហថា គាត់ត្រូវបានតែងតាំងចំនួនបីដងដោយបក្ស ហើយរាល់ពេលតែងតាំងម្តងៗ គាត់មានសិទ្ធិគ្រប់គ្រងមនុស្សច្រើនឡើងៗ ។ គាត់បាននិយាយទៀតថា អៀង សារី គឺជា"គណៈភូមិភាគ"តែគាត់មិនដឹងថា អៀង សារី មានកាន់តំណែងអ្វីទៀតទេ ។ គាត់បានបញ្ជាក់ម្តងទៀតថា គាត់បានជួប អៀង សារី ក្នុងអំឡុងវគ្គរៀនសូត្រកាលនោះ អៀង សារី ប្រើឈ្មោះគាត់ពិតផងនិងឈ្មោះបដិវត្តន៍ផងគឺ "វ៉ាន់" ។ ក្វាន ហ៊ីត បានបន្តទៀតថា នៅពេលដែលតំបន់ដែលគាត់រស់នៅត្រូវអាមេរិកទម្លាក់គ្រាប់បែកក្នុងអំឡុងពេលសង្គ្រាមស៊ីវិល គាត់បានដកថយទៅនៅមូលដ្ឋានមន្ទីរ"ក-៥" ជាមួយនឹងមេដឹកនាំ និងជនបដិវត្តន៍ផ្សេងទៀត ។

ក្រោយមក ក្វាន ហ៊ីត ត្រូវបានសួរអំពីអ្វីដែលគាត់បាននិយាយកាលពីលើកមុនដែលនិយាយថា គាត់និងនិងកម្មាភិបាលចំនួនដប់នាក់ទៀតនៅភូមិភាគឥសាន្តត្រូវបានចាប់ខ្លួនក្នុងឆ្នាំ១៩៧៨រួមទាំង រម៉ម យុន ផង ។ ពេលនោះ ក្វាន ហ៊ីត បានអះអាងថា គាត់បានធ្វើដំណើរទៅភ្នំពេញតាមបទបញ្ជាក្នុងឆ្នាំ១៩៧៨ ហើយពេលមកដល់ភ្នំពេញភ្លាម គាត់និងក្រុមរបស់គាត់ត្រូវបានណែនាំឲ្យសរសេរប្រវត្តិរូប រួចឲ្យទៅធ្វើការដាំបន្លែ ។ គាត់បាននិយាយទៀតថា មួយខែក្រោយពីគាត់មកដល់ នៅព្រឹកមួយ គាត់ត្រូវបាននាំយកទៅជិរ៉ុំកែប្រែវត្តស្លែង ជាកន្លែងដែលគាត់ធ្វើស្រែ គាត់បានឃើញមនុស្សចំនួន៤០០នាក់នៅទីនោះដែរ ។ ក្វាន ហ៊ីត បាននិយាយទៀតថា ប្រពន្ធរបស់បុរសដែល"បាត់ខ្លួន"

*ត្រូវបានយកទៅធ្វើស្រែនៅទីនោះ ហើយនៅកន្លែងនោះមានក្មេងៗយ៉ាងច្រើននាក់កំពុងយំ ។ គាត់បាននិយាយទៀតថា នៅពេលដែលគាត់កំពុងតែកាប់គាស់នៅក្នុងស្រែ តែងតែមានសន្តិសុខមកហៅមនុស្ស និងយកទៅបាត់ដោយមិនឃើញត្រលប់មកវិញទេ ។ នៅពេលនោះ គាត់មិនដឹងថា មនុស្សដែលបាត់ខ្លួននោះត្រូវបាននាំយកទៅទួលស្លែងទេ ក្រោយមកទើបគាត់បានដឹង ។ ក្លាន ហ៊ីត បានបញ្ជាក់ទៀតថា គាត់មិនត្រូវបាននាំទៅគុកទួលស្លែងដោយសារតែវៀតណាមបានដល់ទាន់ពេល ។*

*គាត់បានផ្តល់សក្ខីកម្មទៀតថា គាត់ត្រូវបានសួរអំពីទំនាក់ទំនងជាមួយវៀតណាម កាលពីគាត់នៅវត្តស្លែង តែកាលនោះគាត់បានឆ្លើយថា គាត់មិនស្គាល់វៀតណាមយ៉ាងម៉េចទេ គាត់ឆ្លើយទៀតថា បញ្ហាជាមួយវៀតណាមគឺ «ស្រេចតែអង្គការប៉ុណ្ណោះ» ។*

*មេធាវីរបស់ អៀង សារី បានបញ្ចប់ការសាកសួរត្រឹមនេះ ហើយក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន បានប្រកាសថា ខ្លួនមិនមានសំនួរអ្វីសួរទៅសាក្សីទេ ។*

*បន្ទាប់មក អង្គជំនុំជម្រះបានផ្តល់ឱកាសឲ្យ ក្លាន ហ៊ីត និយាយអំពីផលប៉ះពាល់ដែលគាត់បានទទួលរងដោយរបបខ្មែរក្រហម ដោយបានណែនាំទៅ ក្លាន ហ៊ីត ឲ្យនិយាយក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ។ ពេលនោះ ក្លាន ហ៊ីត មិនចង់និយាយអ្វីទាំងអស់ ហើយសក្ខីកម្មរបស់គាត់បានបញ្ចប់ត្រឹមនេះ ។ ក្រោយពី ក្លាន ហ៊ីត បញ្ចប់ការធ្វើសក្ខីកម្ម ចៅក្រម និល ណុន បានប្រកាសថា ដោយសារតែពេលនេះយឺតបន្តិចហើយ (ម៉ោង៣:៤០រសៀល) អង្គសវនាការមិនអាចចាប់ផ្តើមប្រធានបទថ្មីបានទេ ។ ដូច្នេះអង្គសវនាការប្រកាសផ្អាក និងចាប់បន្តដំណើរការសវនាការនៅថ្ងៃស្អែកទៀត វេលាម៉ោង ៩:០០ព្រឹក ។*

**- ចប់ -**